ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ
១៣២ ចុះថ្ងៃទី ០៧.០២.២០២០
សំណុំរឿងជំនុំជម្រះលេខ
៦០៥ ចុះថ្ងៃទី ២៧.០៥.២០២០
សាលក្រមលេខ: ៨២ "ជ"
ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

តុលាការដំបូងខេត្តសៀមរាប បានបើកសវនាការជាសាធារណៈ
នៅនាទីសាលសវនាការលេខ ២A នៃសាលាដំបូងខេត្តសៀមរាប
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០ វេលារសៀល។
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២០ វេលាព្រឹក។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៣២ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០ និងសំណុំរឿងជំនុំជម្រះលេខ: ៦០៥ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២០ ដែលមានជនជាប់ចោទ៖

១- ឈ្មោះ [redacted] ឿយ ភេទប្រុស អាយុ ៤៤ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួនភូមិត្រាវកៀត ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរស៊ីឈ្នួលដឹកគោ កម្រិតវប្បធម៌ថ្នាក់ទី៦ ឪពុកឈ្មោះ [redacted] ឿង (ស) ម្ដាយឈ្មោះ ឈាន (ស) ប្រពន្ធឈ្មោះ [redacted] សារ៉ា (រ) មានកូន៤នាក់ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ឃាត់ខ្លួនថ្ងៃទី ០៦.០២.២០២០។
- ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ១៤៥ (ឆ) ចុះថ្ងៃទី ០៧.០២.២០២០។

២- ឈ្មោះ [redacted] ជា ភេទប្រុស អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូ [redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួនភូមិប៉ាតត ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរអ្នកទិញគោ កម្រិតវប្បធម៌ថ្នាក់ទី៥ ឪពុកឈ្មោះ [redacted] អ៊ាន (រ) ម្ដាយឈ្មោះ [redacted] ខាត (ស) ប្រពន្ធឈ្មោះ [redacted] យឹង (រ) មានកូន៣នាក់ ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ឃាត់ខ្លួនថ្ងៃទី ០៦.០២.២០២០។

- ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ១៤៦ (ខ) ចុះថ្ងៃទី ០៧.០២.២០២០។

៣- ឈ្មោះ [redacted] **ឈុត** ហៅ [redacted] **បារាំង** ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្នភូមិតាសៀន ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌គ្មាន ឪពុកឈ្មោះ [redacted] ឈឿន (រ) ម្ដាយឈ្មោះ [redacted] សៀន (ស) ប្រពន្ធឈ្មោះ [redacted] ហុម (រ) មានកូន២នាក់ ទោសពីមុនគ្មាន។ (គេចខ្លួន)

៤- ឈ្មោះ [redacted] **ឌី** ភេទប្រុស អាយុ ៥៧ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្នភូមិគោករមាស ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ កម្រិតវប្បធម៌គ្មាន ឪពុកឈ្មោះ ឈឹង (ស) ម្ដាយឈ្មោះ [redacted] ចែម (ស) ប្រពន្ធឈ្មោះ [redacted] សុជា (រ) មានកូន២នាក់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ត្រូវជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ដោយមានលោក [redacted] មានអាសយដ្ឋាននៅការិយាល័យមេធាវីនាគព័ន្ធ ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ,លោក [redacted] មានអាសយដ្ឋាននៅការិយាល័យមេធាវី [redacted] ធីអេសអិន ស្ថិតនៅផ្ទះលេខ ៦D5 ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប , លោក [redacted] មានអាសយដ្ឋាននៅការិយាល័យមេធាវី [redacted] ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ។

- ដោយមានលោក [redacted] មានអាសយដ្ឋាននៅការិយាល័យមេធាវីខេមបូអង្គរ ស្ថិតនៅផ្ទះលេខ ៣៣៩ បុរីសៀងណាំ ភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ជា* ។

- ដោយមានលោក [redacted] មានអាសយដ្ឋាននៅការិយាល័យមេធាវីបន្ទាយក្ដី ស្ថិតនៅអគារលេខ ៣៦$E_3$ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] ឌី ។

## **<u>ភាគីដើមបណ្ដឹងរដ្ឋប្បវេណី</u>**

- ឈ្មោះ [redacted] **ឈច់** ភេទប្រុស អាយុ ៦២ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៤២៩ អយ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ២៥០៥ ពស.ព្រស

(ទ) ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខៈ ១០២១ ពស.ព្រជ (ក) ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## ឯអង្គហេតុកើតមានឡើងដូចតទៅ

. កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ៦ ម៉ ៤៥ នាទី មានករណី អំពើលួចមានស្ថានទម្ងន់ទោស កើតឡើងនៅចំណុចភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ភ្លៀយ ,ឈ្មោះ [redacted] ជា ,ឈ្មោះ [redacted] ឈុត ហៅ [redacted] បាវាំង និងឈ្មោះ [redacted] នី បានធ្វើសកម្មភាពលួចគោញីចំនួន ២ (ពីរ) ក្បាល របស់ជនរងគ្រោះឈ្មោះ [redacted] ឈង់ ភេទប្រុស អាយុ ២៣ ឆ្នាំ ខណៈពេលដែលជនជាប់ចោទខាងលើកំពុងតែធ្វើសកម្មភាពក៏ត្រូវបានកម្លាំងអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគងឃាត់ខ្លួនបានចំនួន២នាក់ មានឈ្មោះ [redacted] ភ្លៀយ និងឈ្មោះ [redacted] ជា រីឯបក្ខពួក២នាក់ទៀតបានរត់គេចខ្លួនបាត់។

## សំអាងហេតុ

- ជនជាប់ចោទឈ្មោះ [redacted] ភ្លៀយ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនវេលាម៉ោងប្រហែល៤យប់ ខណៈពេលខ្លួនរង់ចាំដឹកគោឲ្យឈ្មោះ [redacted] ជា។ ខ្លួនស៊ីឈ្នួលដឹកគោតាមរ៉ឺម៉កឲ្យឈ្មោះ [redacted] ជា បាន៩ខែ ក្នុងមួយជើងតម្លៃ ២០០.០០០ ៛ (ម្ភៃម៉ឺនរៀល) ដោយដឹកពីដំដែកទៅម្តុំស្ពាននាគ ហើយដឹកពេលថ្ងៃបានច្រើនដងមិនចាំចំនួនជើង រីឯពេលយប់ដឹកបាន៤ដង ហើយលើកទី១ ដល់ទី៣ ដឹកគោម្តង២ក្បាល និងលើកទី៤ មិនទាន់បានដឹកផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។ កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង១០យប់ ឈ្មោះ [redacted] ជា បានទូរស័ព្ទមកខ្លួនឲ្យទៅដឹកគោឲ្យគាត់នៅម្តុំស្ពានក្អែក ស្រុកប្រាសាទបាគង ដោយគាត់ប្រាប់ថាប្រញាប់យកគោឲ្យគេ ខ្លួនក៏ទៅដល់កន្លែងកើតហេតុប្រហែលម៉ោង៣ទៀបភ្លឺ បានជួបឈ្មោះ [redacted] ជា។ បាននាំខ្លួនទៅដឹកគោ២ក្បាលដែលមានអ្នកដើរដឹកគោ២នាក់ មិនស្គាល់ឈ្មោះពួកគេទេ ដោយពេលនោះឈ្មោះ [redacted] ជា ជិះម៉ូតូម្នាក់ឯងនាំផ្លូវទៅដឹកគោ ពេលដែលខ្លួនឈប់រ៉ឺម៉ករង់ចាំដឹកគោស្រាប់តែឃើញឡានសមត្ថកិច្ចមកដល់ ហើយឈ្មោះ [redacted] ជា និង២នាក់នោះបានរត់គេចបាត់ នៅសល់ខ្លួនម្នាក់ឯងសមត្ថកិច្ចបានចាប់ខ្លួនតែម្តង រីឯឈ្មោះ [redacted] ជា បានប្រហែលកន្លះម៉ោងទើបសមត្ថកិច្ចឃាត់ខ្លួនបានដែរ។ ខ្លួនមិនបានចូលរួម ឃុបឃិតគំនិតលួចគោគេទេ គ្រាន់តែស៊ីឈ្នួលដឹកគោប៉ុណ្ណោះ ដោយត្រឹមតែដឹងថាឈ្មោះ [redacted] ជា ជាអ្នករកស៊ីទិញលក់គោ មិនដឹងថាគាត់ជាអ្នកលួចគោគេឡើយ។ សូមតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ខ្លួនមិនបានប្រព្រឹត្តដូចការចោទនោះទេ។

- ជនជាប់ចោទឈ្មោះ [redacted] ជា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនរកស៊ីទិញលក់គោ៣ឆ្នាំហើយ ដោយទិញតែគោស្របច្បាប់មានលិខិតអនុញ្ញាតប៉ុណ្ណោះ ប៉ុន្តែរយៈពេល៣ខែចុងក្រោយ ខ្លួនបានទិញគោមិនស្របច្បាប់ (គោដែលចោរលួចបាន) ដែលតែងតែទិញពេលយប់ ហើយម្តងៗខ្លួនតែងជួលឈ្មោះ [redacted] ភ្លៀយ ឲ្យជួយដឹកក្នុងមួយជើងតម្លៃឈ្នួល ២០០.០០០ ៛ (ម្ភៃម៉ឺនរៀល) ដោយគាត់មានរ៉ឺម៉កសម្រាប់ដឹកគោ។ ខ្លួនធ្លាប់ជួលគាត់ដឹកគោតាំងពីខែឧសភា ឆ្នាំ ២០២០ មកម្ល៉េះ ទាំងគោស្របច្បាប់ និងគោមិនស្របច្បាប់ ហើយគោស្របច្បាប់ដឹកពេលថ្ងៃ គោខុសច្បាប់ដឹកពេលយប់។ ខ្លួនធ្លាប់ទិញគោចោរលួច៤ដង គឺលើកទី១ នៅស្រុកសូទ្រនិគម៤ដង សរុប៥ក្បាល ទិញពីឈ្មោះ [redacted] ឈុត ហៅបាវាំង ,លើកទី២ នៅស្រុកជីក្រែង ១ដង សរុប២ក្បាល ទិញពីឈ្មោះ

[redacted] ឈុត ហៅបាភាំង ,លើកទី៣ នៅឃុំអំពិល ស្រុកប្រាសាទបាគង ១ដង សរុប៣ក្បាល (មានកូនតូច១ក្បាល) ទិញពីឈ្មោះ [redacted] ឈុត ហៅបាភាំង និងលើកទី៤ នៅចំណុចភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដោយមិនទាន់បានទិញផង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន។ កាលពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ឈ្មោះ [redacted] ឈុត ហៅបាភាំង និងឈ្មោះ [redacted] ឌី បានទូរស័ព្ទមកខ្លួនថាទិញគោអត់ គាត់មានគោលក់២ក្បាល ខ្លួនប្រាប់ថាទិញ ដោយណាត់គ្នាយកគោនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ម៉ោង២យប់ ដោយខ្លួនជិះម៉ូតូម៉ាក Zoomer X ពណ៌ខ្មៅលាយក្រហម រីឯឈ្មោះ[redacted] ភ្លៀយ ជិះរ៉ឺម៉កដឹកគោទៅដល់ចំណុចទទួលទិញគោម៉ោងប្រហែល ៣ទៀបភ្លឺ មិនទាន់បានទិញផងខ្លួន និងឈ្មោះ [redacted] ភ្លៀយ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន រីឯឈ្មោះ [redacted] ឈុត ហៅ បាភាំង និងឈ្មោះ [redacted] ឌី បានគេចខ្លួនបាត់។ ចំពោះគោ២ក្បាលនោះសមត្ថកិច្ចបានរឹបអូស ហើយប្រគល់ឲ្យម្ចាស់ដើមវិញហើយ។ សូមតុលាការជួយសម្រាលទោសដល់ខ្លួនផង ខ្លួនទទួលស្គាល់កំហុសហើយ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឈទ់** បានឆ្លើយបញ្ជាក់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា៖ ជារៀងរាល់ល្ងាចខ្លួនតែងតែយកគោចំនួន៦ក្បាល (ញី៥ ឈ្មោល១ សំបុរក្រហម ២ ស ២) ទៅឲ្យដេកនៅវាលស្រែខាងជើងផ្ទះចំងាយ៣៥ម៉ែត្រ។ លុះដល់ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង៥ល្ងាច ខ្លួនបានយកគោ៦ក្បាលនោះទៅចងទុកនៅកន្លែងដដែលដូចសព្វដង និងបានដេកលង់លក់ដល់ម៉ោង៣ទៀបភ្លឺថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ ខ្លួនបានភ្ញាក់ក្រោកឈ្លូលពិលមើល ស្រាប់តែបាត់គោញី២ក្បាល សំបុរស ក៏គិតថាចោរលួចដឹកយកទៅបាត់ ហើយបានទៅប្រាប់ប្រជាការពារភូមិដែលនៅជិតនោះ ដោយទាក់ទងតាមអាយកូមទើបដឹងថាសមត្ថកិច្ចកំពុងចាប់បានចោរលួចគោ ហើយខ្លួនបានទៅមើលគឺពិតជាគោរបស់ខ្លួនប្រាកដមែន។ សព្វថ្ងៃខ្លួនបានទទួលគោញីទាំង២ក្បាលរបស់ខ្លួនវិញហើយ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ តម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខ: ៤២៩ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០ ទុកជាបានការដដែល និងប្តឹងសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ភ្លៀយ* បានធ្វើសន្និដ្ឋានការពារថា៖ ក្នុងរឿងនេះកូនក្តីខ្លួនពិតជាបានដឹកគោមែន ដោយមិនដឹងថាគោនោះបានមកពីលួចគេឡើយ គ្រាន់តែស៊ីឈ្នួលដឹកគោយកកម្រៃប៉ុណ្ណោះមិនថាយប់ មិនថាថ្ងៃឡើយ បើគាត់ដឹងថាគោនោះលួចគេក៏មិនដឹកដែរ ហើយសមត្ថកិច្ចបានដកហូតម៉ូតូរ៉ឺម៉កគាត់ទៀតផង ដោយមិនមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើកូនក្តីខ្លួនឡើយ។ ហេតុនេះខ្លួនសំណូមពរតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ និងសម្រេចប្រគល់រ៉ឺម៉កម៉ូតូឲ្យទៅកូនក្តីខ្លួនវិញ ដោយអនុគ្រោះ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] *ជា* បានធ្វើសន្និដ្ឋានការពារថា៖ ក្នុងរឿងនេះកូនក្តីខ្លួនមិនដឹងថាគោនោះបានមកពីការលួចគេទេ ហើយសមត្ថកិច្ចបានដកហូតម៉ូតូមួយគ្រឿងជារបស់កូនប្រសារកូនក្តីខ្លួនផងដែរ។ ហេតុនេះខ្លួនសំណូមពរតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ និងសម្រេចប្រគល់ម៉ូតូដែលបានដកហូតឲ្យទៅកូនប្រសារកូនក្តីខ្លួនវិញ ដោយអនុគ្រោះ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ឈុត* ហៅ *ឈឿន បាភាំង* និងឈ្មោះ [redacted] ឌី បានធ្វើសន្និដ្ឋានការពារថា៖ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ភ្លៀយ និងឈ្មោះ [redacted] ជា

ថាមិនស្គាល់កូនក្តីខ្លួនឡើយ ដោយមិនមានភាពច្បាស់លាស់ទេ គឺនៅមានវិមតិសង្ស័យច្រើន។ ហេតុនេះខ្លួនសំណូមពរតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ ដោយអនុគ្រោះ។

ផ្អែកតាមកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ការអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានពិនិត្យភស្តុតាងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ការកត់សម្គាល់របស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សា ត្រឹមត្រូវសតាមច្បាប់

**ក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តសៀមរាប**

**យល់ឃើញថា**

- តាមរយៈដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ២៩០៥ ពស.ព្រស (ទ) ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ជា* ,ឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* ទៅជំនុំជម្រះពីបទ: *លួចមានស្ថានទម្ងន់ទោស* ប្រព្រឹត្តនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- តាមរបាយការណ៍សំយោគលេខ: ៦៣/២០ នបសបាគ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់អធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង បានបញ្ជាក់ថា៖ កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ៣ ម៉ ០០ នាទីទៀបភ្លឺ ជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ជា* ,ឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* ពិតជាបាននាំគ្នាធ្វើសកម្មភាពយកលួចយកគោញីចំនួន២ក្បាលរបស់ជនរងគ្រោះឈ្មោះ [redacted] *ឈង់* នៅចំណុចភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រាកដមែន។

- ចម្លើយសារភាពរបស់ជនជាប់ចោទ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងវត្ថុតាងដែលដកហូតបានជាក់ស្តែងបង្ហាញឲ្យឃើញថា៖ កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ៦ ម៉ ៤៥ នាទីមានករណីអំពើលួចមានស្ថានទម្ងន់ទោស កើតឡើងនៅចំណុចភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប បង្កឡើងជនជាប់ចោទឈ្មោះ [redacted] ភ្លឿយ ,ឈ្មោះ [redacted] ជា ,ឈ្មោះ [redacted] ឈុត ហៅ [redacted] បារាំង និងឈ្មោះ [redacted] ឌី បានធ្វើសកម្មភាពលួចគោញីចំនួន ២ (ពីរ) ក្បាលរបស់ជនរងគ្រោះឈ្មោះ [redacted] ឈង់ ភេទប្រុស អាយុ ២៣ ឆ្នាំ ខណៈពេលដែលជនជាប់ចោទខាងលើកំពុងតែធ្វើសកម្មភាពក៏ត្រូវបានកម្លាំងអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគងឃាត់ខ្លួនបានចំនួន២នាក់មានឈ្មោះ [redacted] ភ្លឿយ និងឈ្មោះ [redacted] ជា រីឯបក្ខពួក២នាក់ទៀតបានរត់គេចខ្លួនបាត់ប្រាកដមែន។

- ជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ជា* ,ឈ្មោះ [redacted] *ឈុត* ហៅ [redacted]

*បារាំង* និងឈ្មោះ [redacted] *ឌី* មានចេតនាទុច្ចរិត ដោយបាននាំគ្នាធ្វើសកម្មភាពដកហូតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃតាមគ្រប់មធ្យោបាយ ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយការប្រើហិង្សា ឬការកាប់គាស់ទម្លុះទម្លាយ ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទៈ *លួចមានស្ថានទម្ងន់ទោស* ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ តម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខៈ ៤២៩ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០ ទុកជាបានការដដែល និងប្តឹងសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ឃើញថាការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាចំពោះការប្តឹងសុំនេះ។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ដែលបានស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ និងសម្រេចប្រគល់រ៉ឺម៉កម៉ូតូឲ្យទៅកូនក្តីខ្លួនវិញ ឃើញថាមិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការពិចារណាបានទេ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ដា* ដែលបានស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ និងសម្រេចប្រគល់ម៉ូតូឲ្យទៅកូនប្រសារកូនក្តីខ្លួនវិញ ឃើញថាមិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការពិចារណាបានទេ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* ដែលបានស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ ឃើញថាមិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការពិចារណាបានទេ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

- ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ដា* , ឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* មានបញ្ហាខាងស្មារតីឡើយ ជនជាប់ចោទពិតជាបានយល់ដឹងពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន។

• ***ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថា៖***

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ដា* ,ឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* ពីបទៈ *លួចមានស្ថានទម្ងន់ទោស* ប្រព្រឹត្តនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] *ភឿយ* ,ឈ្មោះ [redacted] *ដា* ,ឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] *ឌី* ធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ សន្តិសុខ សណ្តាប់

ផ្ទាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

- ជនជាប់ចោទឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* និងឈ្មោះ [redacted] ឌី អាចត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ ដោយគ្មានការព្យួរ គប្បីតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទទាំងពីររូបនេះតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- វត្ថុតាងដែលសមត្ថកិច្ចដកហូតបានមានដូចជា៖

ក- ម៉ូតូមួយគ្រឿងម៉ាក HONDA ZOOMER X ពណ៌ខ្មៅលាយក្រហម ស៊េរីឆ្នាំ ២០១៨ មានលេខតួ និងលេខម៉ាស៊ីន MLHJF6233J5025733 ពាក់ផ្លាកលេខ សៀមរាប ១AC-៨៥៧៥ និងម៉ូតូមួយគ្រឿងម៉ាកសាន់យ៉ាន់ C150 ពណ៌ស គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉កពីក្រោយ (សព្វថ្ងៃកំពុងរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង) ព្រមទាំងទូរស័ព្ទមួយគ្រឿងម៉ាកNOKIA ចុចពិល មានស៊ីម Cellcard និង metfone ពណ៌ខ្មៅ, ទូរស័ព្ទមួយគ្រឿងម៉ាក NOKIA ចុចពិល មានស៊ីម metfone ពណ៌ខៀវ , កាបូបដៃចំនួន ១ (មួយ) ,ប្រាក់ដុល្លាក្លែងក្លាយ (លុយសែន) ចំនួន ៨០០ $ (ប្រាំបីរយដុល្លារអាមេរិក) ,ប្រាក់រៀលខ្មែរចំនួន ៣៦០០ ៛ (បីពាន់ប្រាំមួយរយរៀល) និងបណ្ណសម្គាល់យានយន្តចំនួន ១ (មួយ) ដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ១២១ ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប គឺជាវត្ថុដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

ខ- អត្តសញ្ញាណប័ណ្ណឈ្មោះ [redacted] *គៀយ* ចំនួន ១ (មួយ) ដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ១២១ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប គឺជាសំភារៈសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន មិនមែនជាវត្ថុដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសនោះទេ គប្បីតុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] *ឈង់* បានទទួលគោរបស់ខ្លួនវិញហើយតាមរយៈកំណត់ហេតុប្រគល់ និងទទួលគោ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់អធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលខ្លួនមកទាមទារសំណងជម្ងឺចិត្តតាមការកោះហៅរបស់តុលាការនោះទេ គប្បីតុលាការមិនពិនិត្យពិចារណាអំពីបញ្ហានេះឡើយ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១- ផ្តន្ទាទោស៖

ក- ឈ្មោះ [redacted] **គៀយ** ភេទប្រុស អាយុ ៤៤ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (បួន) **ឆ្នាំ** គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ។

ខ- ឈ្មោះ [redacted] **ដា** ភេទប្រុស អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (**បួន**) **ឆ្នាំ** គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ។

គ- ឈ្មោះ [redacted] **ឈុត** ហៅ **ឈឿន បារាំង** ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (**បួន**) **ឆ្នាំ** គិតពីថ្ងៃចាប់ខ្លួនបាន។

ឃ- ឈ្មោះ [redacted] **ឌី** ភេទប្រុស អាយុ ៥៧ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (**បួន**) **ឆ្នាំ** គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង

ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- ចេញដីកាបង្គាប់ឲ្យកាត់ខ្លួនឈ្មោះ [redacted] **ឈុត** ហៅ [redacted] **បារាំង** និងឈ្មោះ [redacted] **ឌី** មកផ្តន្ទាទោស តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣- វត្ថុតាងដែលសមត្ថកិច្ចដកហូតបានមានដូចជា៖

ក- ម៉ូតូមួយគ្រឿងម៉ាក HONDA ZOOMER X ពណ៌ខ្មៅលាយក្រហម ស៊េរីឆ្នាំ ២០១៨ មានលេខតួ និងលេខម៉ាស៊ីន MLHJF6233J5025733 ពាក់ផ្លាកលេខ សៀមរាប ១AC-៨៥៧៥ និងម៉ូតូមួយគ្រឿងម៉ាកសាន់យ៉ាង C150 ពណ៌ស គ្មានផ្លាកលេខ មានសណ្តោងរ៉ឺម៉កពីក្រោយ (សព្វថ្ងៃកំពុងរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង) ព្រមទាំងទូរស័ព្ទមួយគ្រឿងម៉ាកNOKIA ចុចពិល មានស៊ីម Cellcard និង metfone ពណ៌ខ្មៅ, ទូរស័ព្ទមួយគ្រឿងម៉ាក NOKIA ចុចពិល មានស៊ីម metfone ពណ៌ខៀវ , កាបូបដៃចំនួន ១ (មួយ) ,ប្រាក់ដុល្លាក្លែងក្លាយ (លុយសែន) ចំនួន ៨០០ $ (ប្រាំបីរយដុល្លារអាមេរិក) ,ប្រាក់រៀលខ្មែរចំនួន ៣៦០០ ៛ (បីពាន់ប្រាំមួយរយរៀល) និងបណ្ណសម្គាល់យានយន្តចំនួន ១ (មួយ) ដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ១២១ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប **សម្រេចរឹបអូស** តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

ខ- អត្តសញ្ញាណប័ណ្ណឈ្មោះ [redacted] *ភៀយ* ចំនួន ១ (មួយ) ដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ១២១ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប **សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ** តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] *ភៀយ* ,ឈ្មោះ [redacted] *ដា* និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] *ឈុត* ហៅ [redacted] *បារាំង* ,ឈ្មោះ [redacted] ឌី។

- ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់៕

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាបថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]